ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៧៧...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០៥ ។

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក សរសេរកាត់ថា : "**គ.ស.ច.គ.**" ។

**មាត្រា ២ :** គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក បង្កើតឡើងក្នុងគោលបំណង ៖

-ប្រមូលកម្លាំង ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ កិច្ចសហការ និងការសម្របសម្រួលរវាងក្រសួង និងស្ថាប័ន ដែលពាក់ព័ន្ធ សំដៅចាត់វិធានការបង្ការ ទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរ ផ្លូវគោក ឱ្យដល់កម្រិតទាបបំផុត

- ការពារអាយុជីវិតប្រជាជន និងបង្ការការខូចខាតបាត់បង់ទ្រព្យសម្បត្តិឯកជន និងសាធារណៈដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរ និងជាហេតុធ្វើឱ្យប៉ះពាល់ ដល់សេដ្ឋកិច្ច សង្គម និងផលិតផលសរុបក្នុងស្រុក
- ធានាឱ្យបានរឹងមាំនូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរផ្លូវគោក ។

**មាត្រា ៣ :** គណៈកម្មាធិការជាតិ មានគណៈកម្មាធិការខេត្ត ក្រុង ជាជំនួយការ។ គណៈកម្មាធិការជាតិមានអគ្គលេខាធិការដ្ឋានមួយ និងគណៈកម្មាធិការខេត្ត ក្រុង នីមួយៗ មានលេខាធិការដ្ឋានមួយ ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ៤ :** សមាសភាព នៃគណៈកម្មាធិការជាតិមានដូចខាងក្រោម ÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៥-អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិកអចិន្ត្រៃយ៍ |
| ៦-រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៤ -រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥ -រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៦ -រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៧ -រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨ -មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩ -អគ្គលេខាធិការសមាគមជាតិកាកបាទក្រហមកម្ពុជា | សមាជិក |
| ២០ -អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក ។ |

**មាត្រា ៥ :** សមាសភាព នៃគណៈកម្មាធិការខេត្ត ក្រុង មានដូចខាងក្រោម÷

| | |
|---|---|
| ១-អភិបាលខេត្ត ក្រុង | ប្រធាន |
| ២-ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | អនុប្រធាន |
| ៣-ស្នងការនគរបាលខេត្ត ក្រុង | អនុប្រធាន |
| ៤-អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | សមាជិកអចិន្ត្រៃយ៍ |
| ៥-មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ក្រុង | សមាជិក |
| ៦-ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង | សមាជិក |
| ៧-ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង | សមាជិក |
| ៨-ប្រធានមន្ទីរបរិស្ថាន ខេត្ត ក្រុង | សមាជិក |
| ៩-ប្រធានមន្ទីរព័ត៌មាន ខេត្ត ក្រុង | សមាជិក |
| ១០-ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង | សមាជិក |
| ១១-ប្រធានមន្ទីរទេសចរណ៍ ខេត្ត ក្រុង | សមាជិក |
| ១២-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង | សមាជិក |
| ១៣-ប្រធានសាខាកាកបាទក្រហមខេត្ត ក្រុង | សមាជិក ។ |

**មាត្រា ៦ :** គណៈកម្មាធិការខេត្ត ក្រុង នីមួយៗ ត្រូវបង្កើតក្រុមការងារសុវត្ថិភាពចរាចរផ្លូវគោក នៅតាមស្រុក ខណ្ឌ ឃុំ សង្កាត់ ជាជំនួយការ ដើម្បីងាយស្រួលក្នុងការប្រមូលរបាយការណ៍ និងការងារផ្តល់ព័ត៌មាន ផ្សព្វផ្សាយពីថ្នាក់ជាតិ ទៅមូលដ្ឋាន និងពីមូលដ្ឋានទៅថ្នាក់ជាតិ ។

**មាត្រា ៧ :** សមាសភាព នៃអគ្គលេខាធិការដ្ឋានរបស់ គ.ស.ច.គ. មានដូចខាងក្រោម ÷

| | |
|---|---|
| ១- អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន | ប្រធាន |
| ២- អគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការ | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | អនុប្រធាន |
| ៤- ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ៦- តំណាងប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧- តំណាងប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- តំណាងប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ | សមាជិក ។ |

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ មានទីតាំងនៅអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៨ :** សមាសភាពរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្ត ក្រុង មានដូចខាងក្រោម ÷

| | |
|---|---|
| ១- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | ប្រធាន |
| ២- អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | អនុប្រធាន |
| ៣- នាយកការិយាល័យដឹកជញ្ជូន ខេត្ត ក្រុង | សមាជិក |
| ៤-មន្ត្រីជំនាញ ០៣នាក់ នៃការិយាល័យដឹកជញ្ជូន ខេត្ត ក្រុង | សមាជិក ។ |

លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្ត ក្រុង មានទីតាំងនៅមន្ទីរសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៣

## ភារកិច្ច

**មាត្រា ៩ :** គ.ស.ច.គ.មានភារកិច្ច ÷

ក- កសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ សកម្មភាព គ្រប់គ្រងសន្តិសុខ សុវត្ថិភាពចរាចរផ្លូវគោក ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យសម្រេច ។

ខ- ដាក់ឱ្យអនុវត្តផែនការសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោក រួមទាំងផ្លាកសញ្ញាផ្សេងៗ ។

គ- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាព សុវត្ថិភាពចរាចរផ្លូវគោក ។

ឃ-ណែនាំអំពីនីតិវិធីសម្រាប់ការចាត់តាំង អនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោក ។

ង- ធ្វើសហប្រតិបត្តិការ និងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល ដើម្បីការអនុវត្តផែនការសកម្មភាព សុវត្ថិភាពចរាចរ ឱ្យមានប្រសិទ្ធភាព ។

ច- ស្វែងរកជំនួយពីបរទេស ក្រុមហ៊ុនឯកជន ឬអង្គការផ្សេងៗ ។

**មាត្រា ១០ :** គណៈកម្មាធិការខេត្ត ក្រុង មានភារកិច្ច ÷

ក- អនុវត្តផែនការយុទ្ធសាស្ត្រ និងបទដ្ឋាននានា ដែលដាក់ចេញដោយគណៈកម្មាធិការជាតិ ។

ខ- លើកគម្រោងចំណាយផ្សេងៗ ប្រចាំឆ្នាំពាក់ព័ន្ធទៅនឹងវិធានការ សម្រាប់កាត់បន្ថយគ្រោះថ្នាក់ចរាចរ ។

គ- បំពេញភារកិច្ចដទៃទៀត ដែលគណៈកម្មាធិការជាតិប្រគល់អោយ ។

**មាត្រា ១១ :** អគ្គលេខាធិការដ្ឋានរបស់ គ.ស.ច.គ. មានភារកិច្ច ÷

ក- ជាសេនាធិការ និងជាជំនួយការ របស់គណៈកម្មាធិការជាតិ ។

ខ- អនុវត្តនូវរាល់សេចក្តីសម្រេច របស់គណៈកម្មាធិការជាតិ ។

គ- ចាត់ចែងផ្សព្វផ្សាយ អប់រំពន្យល់ណែនាំជាសាធារណៈ តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយដល់អ្នកប្រើប្រាស់ផ្លូវ និងប្រជាពលរដ្ឋ ឱ្យស្គាល់ និងយល់ច្បាស់អំពីច្បាប់ និងបទប្បញ្ញត្តិចរាចរ ។

ឃ-ប្រមូលផ្តុំ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ របស់គណៈកម្មាធិការជាតិ ។

ង-ប្រមូលស្ថិតិយានយន្ត គ្រោះថ្នាក់ចរាចរទូទាំងប្រទេសដើម្បីធ្វើការបូកសរុប និងវិភាគរកមូលហេតុ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរ រួចលើកសំណូមពរជូនរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់ ។

ច- បណ្តុះបណ្តាលគ្រូបង្រៀន នៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និងអាជ្ញាធរមូលដ្ឋាន ដើម្បីជួយផ្សព្វផ្សាយ អប់រំ អំពីច្បាប់ចរាចរ ។

ឆ-បណ្តុះបណ្តាលធនធានមនុស្ស លើវិស័យសុវត្ថិភាពចរាចរ ដើម្បីបម្រើសេចក្តីត្រូវការក្នុងគណៈកម្មាធិការជាតិ ។

**មាត្រា ១២ :** លេខាធិការដ្ឋានរបស់គណៈកម្មាធិការខេត្ត ក្រុង មានភារកិច្ច ៖

ក- ជាសេនាធិការ និងជាជំនួយការ របស់គណៈកម្មាធិការខេត្ត ក្រុង ។

ខ- អនុវត្តនូវរាល់សេចក្តីសម្រេច របស់គណៈកម្មាធិការខេត្ត ក្រុង ។

គ- រៀបចំគម្រោងចំណាយសម្រាប់សុវត្ថិភាពចរាចរផ្លូវគោកប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ដើម្បីធ្វើជូនគណៈកម្មាធិការខេត្ត ក្រុង ។

ឃ- ផ្សព្វផ្សាយ អប់រំ ជាសាធារណៈ ដល់អ្នកប្រើប្រាស់ផ្លូវ និងប្រជាពលរដ្ឋឱ្យស្គាល់ និងយល់ច្បាស់ពីច្បាប់ និងបទប្បញ្ញត្តិចរាចរ ។

ង- ស្រង់ស្ថិតិអំពីគ្រោះថ្នាក់ចរាចរ ដែលកើតមាននៅក្នុងខេត្ត ក្រុង និងបញ្ជូនមកអគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិ ។

ច- តាមដានសភាពការណ៍ចរាចរ និងកត់ត្រាទុកកន្លែងណា ដែលមានគ្រោះថ្នាក់ចរាចរ ញឹកញាប់ ។

## ជំពូកទី ៤

## ថវិការបស់គណៈកម្មាធិការជាតិ

**មាត្រា ១៣ :** គណៈកម្មាធិការជាតិ ត្រូវមានថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១៤ :** ប្រភពថវិការបស់គណៈកម្មាធិការជាតិ រួមមាន ៖

- ថវិកាទូទៅរបស់រដ្ឋ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
- ចំណូលបានពីការដាក់ពិន័យបទល្មើសចរាចរ
- ជំនួយបរទេស
- អំណោយរបស់សប្បុរសជន ក្រុមហ៊ុនឯកជន ឬអង្គការផ្សេង ៗ
- ប្រភពចំណូលផ្សេងៗទៀត ។

**មាត្រា ១៥ :**- គណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្ត ក្រុង ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីឱ្យដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្ត ក្រុង មានប្រសិទ្ធភាព ។

- គណៈកម្មាធិការជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- គណៈកម្មាធិការខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៦ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន ។

**មាត្រា ១៨ :** អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា១៧
- ឯកសារ - កាលប្បវត្តិ